# លើកកម្ពស់សមភាពយេនឌ័រនៅក្នុងការអនុវត្តជាក់ស្តែង

វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីសំខាន់ៗ
របស់រដ្ឋបាលរាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ

បង្ហាញដោយ ៖
ក្រុមការងារយេនឌ័រក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប

# មាតិកា

- យេនឌ័រនៅក្នុងផអ៣
- ដំណើរការនៃការធ្វើអោយមានសមភាពយេនឌ័រ
- ផ្តល់គំនិតពីមុន និង ការគិតគូរដែលនាំឱ្យមានសមភាព
- ការពិភាក្សារួម

# ហេតុអ្វីត្រូវគិតគូរពីយេនឌ័រនៅក្នុងផអ៣?



- ព្រោះស្ត្រីតំណាងឱ្យជិត៥២% នៃធនធានមនុស្សក្នុងប្រទេស
- ព្រោះយើងទាំងអស់គ្នាទទួលស្គាល់ថាស្ត្រី និងបុរសសុទ្ធតែមានតួនាទីសំខាន់ដូចៗគ្នាទាំងនៅក្នុងគ្រួសារ និងសង្គម
- ព្រោះយើងមានគោលនយោបាយ ច្បាប់ និងកម្មវិធីដែលលើកកម្ពស់សមភាពយេនឌ័រ

**តើមានអ្វីខ្លះនឹងកើតឡើងនៅក្នុងផអ៣?**

- គោលនយោបាយ និងលិខិតបទដ្ឋានជាច្រើននឹងត្រូវបង្កើតឡើង កែសម្រួលជាថ្មី និងដាក់ឱ្យអនុវត្ត ...
- យន្តការ និងរចនាសម្ព័ន្ធរដ្ឋបាលថ្មីនឹងត្រូវបង្កើតឡើង...

## តើមានអ្វីខ្លះនឹងកើតឡើងនៅក្នុងផអ៣ ?

- ធនធានមនុស្សជាច្រើននឹងត្រូវជ្រើសរើសថ្មី ផ្ទេរ និង ចាត់តាំង ឱ្យទៅបំរើការងារនៅថ្នាក់ក្រោមជាតិ ...
- ប្រព័ន្ធរដ្ឋបាល និងហិរញ្ញវត្ថុថ្មីនឹងដាក់ឱ្យអនុវត្ត...
- សេវាកម្មសាធារណៈមួយចំនួននឹងត្រូវអនុវត្ត...

ដែលអ្វីទាំងនេះគឺជាកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យ ប្រសើរឡើងនូវស្ថានភាពរបស់ស្ត្រី និងបុរសទាំងក្នុងវិស័យ សេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយសំដៅ រួមចំណែកកាត់បន្ថយភាពក្រីក្រ និងសម្រេចនូវគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ។



## ដំណើរការនៃការធ្វើអោយមាន សមភាពយេនឌ័រ

| គ្មានការយល់ដឹង អំពីយេនឌ័រ Gender-blind | មានការយល់ ដឹងពីយេនឌ័រ Gender-sensitive | ឆ្លើយតបនឹង តម្រូវការយេនឌ័រ Gender-responsive | កែប្រែ និងដោះស្រាយ នូវតម្រូវការយេនឌ័រ Gender-transformative: |
|---|---|---|---|

→ → →

## ផ្គត់គំនិតពីមុន និង ការគិតគួរដែលនាំឲមានសមភាព

| ការយល់ឃើញកន្លងមក | ការយល់ឃើញកន្លងមក ដែលនាំឱ្យមានសមភាព |
| --- | --- |
| ស្ត្រី និងបុរសគឺខុសគ្នាពីធម្មជាតិមក ដូច្នេះយើងមិនគួរទៅរំខានធម្មជាតិទេ ។ | ស្ត្រីនិងបុរសមានលក្ខណៈខុសគ្នា ប៉ុន្តែភាពខុសគ្នាជាច្រើនគឺកើតឡើងដោយសារបទពិសោធន៍ខុសគ្នាក្នុងជីវិត ។ |
| បុរសពូកែខាង"ការងារបុរស" ចំណែកស្ត្រីពូកែខាង"ការងារស្ត្រី" | បុរស និងស្ត្រីទាំងអស់មិនមែនសុទ្ធតែពូកែគ្រប់កិច្ចការនោះទេ ប៉ុន្តែស្ត្រីនិងបុរសគ្រប់រូបគួរត្រូវបានផ្តល់ឱកាសដើម្បីស្វែងរកទេពកោសល្យរបស់ខ្លួន ។ |

## ផ្គត់គំនិតពីមុន និង ការគិតគួរដែលនាំឲមានសមភាព (ត)

| ការយល់ឃើញកន្លងមក | ការយល់ឃើញកន្លងមក ដែលនាំឱ្យមានសមភាព |
| --- | --- |
| មានតែស្ត្រីប៉ុណ្ណោះដែលគួរ (ឬអាច) មើលថែរក្សាកុមារបានល្អ ។ | កុមារគួរទទួលបានការថែរក្សាពីឪពុក និងម្តាយតាំងពីវ័យតូចដើម្បីការចំរើនវ័យរបស់គេ ។ |
| ស្ត្រីមិនពូកែធ្វើសេចក្តីសម្រេចចិត្តទេ ។ | ដោយសារស្ត្រីនិងបុរសទទួលបានបទពិសោធន៍ខុសៗគ្នានៅក្នុងជីវិត ដូច្នេះពួកគាត់ធ្វើការសម្រេចចិត្តលើរឿងរ៉ាវផ្សេងៗគ្នា និងប្រើវិធីសម្រេចចិត្តខុសគ្នា ។ |

## ផ្នត់គំនិតពីមុន និង ការគិតគូរដែលនាំឲ្យមានសមភាព (ត)

| ការយល់ឃើញកន្លងមក | ការយល់ឃើញកន្លងមក ដែលនាំឱ្យមានសមភាព |
|---|---|
| ប៉ុន្តែបញ្ហាដែលយើងកំពុងដោះស្រាយគឺភាពក្រីក្រ មិនមែនវិសមភាពយេនឌ័រទេ ! | មានការសិក្សាបង្ហាញថា ៖<br>-ក្នុងចំណោមអ្នកក្រីក្រជាច្រើនគឺជាស្ត្រី<br>- ស្ត្រីនិងបុរសជួបប្រទះបញ្ហា និងដោះស្រាយបញ្ហាមិនដូចគ្នាទេ រួមទាំងបញ្ហាដែលបណ្តាលមកពីភាពក្រីក្រ ។ |

## ផ្នត់គំនិតពីមុន និង ការគិតគូរដែលនាំឲ្យមានសមភាព (ត)

| ការយល់ឃើញកន្លងមក | ការយល់ឃើញកន្លងមក ដែលនាំឱ្យមានសមភាព |
|---|---|
| ធនធានយើងមានកំណត់ដូច្នេះ មិនអាចដោះស្រាយគ្រប់បញ្ហារបស់សហគមន៍ទេ រួមទាំងបញ្ហាវិសមភាពយេនឌ័រ | ការលើកកម្ពស់សមភាពយេនឌ័រមិនមែនជាការទាមទារឱ្យអនុវត្តសកម្មភាពបន្ថែម ឬទាមទារធនធានបន្ថែមរហូតនោះទេ ។ ប៉ុន្តែជាការផ្លាស់ប្តូររបៀបធ្វើការងារដែលទាមទារឱ្យបញ្ចូលការគិតគូរ និងយកចិត្តទុកដាក់លើបញ្ហា និងតម្រូវការរបស់បុរសនិងស្ត្រីក្នុងពេលជាមួយគ្នា ។ |

# សកម្មភាពជាក់លាក់ដើម្បីបង្កើនសមភាពយេនឌ័រ

1. សកម្មភាពជាវិជ្ជមាន (Positive or affirmative action)




2. សកម្មភាពជាក់លាក់សម្រាប់ស្ត្រី (Women-specific activities)



3. សកម្មភាពជាក់លាក់សម្រាប់បុរស (Men-specific activities)



# ការពិភាក្សារួម